ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

លេខ ០០៩ សសរ/គ.ជ.ក.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ... ឆ្នាំ២០០៨

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំ
## គម្រោងវិនិយោគជនបទនិងអភិបាលកិច្ចមូលដ្ឋានដំណាក់កាលទី២
## ដែលគាំទ្រដោយធនាគារពិភពលោក

## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងតាមសំណើរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ។

## សម្រេច

**ប្រការ ១.-**

ត្រូវបាន បង្កើតក្រុមការងាររៀបចំគម្រោង វិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដំណាក់កាលទី២ មានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- ឯកឧត្តម **លេង វី** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាអនុប្រធាន |
| ៣- ឯកឧត្តម **ម៉ាន់ ចំរើន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤- លោក **យិន ម៉ាលីណា** | ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៥- លោក **នី គីមសាន** | ប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ជាសមាជិក |
| ៦- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ជាសមាជិក |
| ៧- តំណាងក្រសួងផែនការ | | ជាសមាជិក |



មហាវិថីព្រះនរោត្តម: គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ "គ.ជ.វ.វ" (អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ)
Norodom Blv, National Committee for the Management of Decentralization and Deconcentration Reform (NCDD) (Ministry of Interior, General Department of Local Administration)

**ប្រការ ២.-**

ក្រុមការងាររៀបចំគម្រោង វិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដំណាក់កាលទី២ មានភារកិច្ចសំខាន់ៗ ដូចខាង ក្រោម :

- ដឹកនាំ រៀបចំតាក់តែង និងចរចា ជាមួយក្រុមបេសកកម្មនៃធនាគារពិភពលោក ក្នុងការរៀបចំ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដំណាក់កាលទី២
- ដឹកនាំ តម្រង់ទិស និងសម្របសម្រួល ដល់ទីប្រឹក្សារៀបចំឯកសារគម្រោង និងទីប្រឹក្សាពាក់ព័ន្ធផ្សេងទៀត ផ្អែកតាមយុទ្ធសាស្ត្រនានានៃកម្មវិធីជាតិ ស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ពិនិត្យឡើងវិញ នូវរបកគំហើញ ដែលបានមកពីការសិក្សាស្រាវជ្រាវពាក់ព័ន្ធនានា ដើម្បីបញ្ចូលនូវអនុសាសន៍សំខាន់ៗ ទៅក្នុងឯកសារគម្រោង សម្រាប់ជួយបង្កើនប្រសិទ្ធភាពនៃការអនុវត្ត
- ពិគ្រោះយោបល់ជាមួយ បណ្តាក្រសួងពាក់ព័ន្ធនៅថ្នាក់ជាតិ អាជ្ញាធរនានានៅថ្នាក់ក្រោមជាតិ និងក្រុមបេសកកម្មនៃធនាគារពិភពលោក និងរៀបចំការពិគ្រោះយោបល់ ជាមួយស្ថាប័ននិងដៃគូរអភិវឌ្ឍន៍ទាំងឡាយ ដែលចាំបាច់
- ពិនិត្យវាយតំលៃអំពីហានិភ័យនានា និងរៀបចំយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ
- ទទួល និងសុំយោបល់ផ្នែកគោលនយោបាយ និងគោលការណ៍ណែនាំពីថ្នាក់ដឹកនាំគ.ជ.វ.វ
- រៀបចំ និងដឹកនាំការប្រជុំពិភាក្សា ជាមួយក្រុមបេសកកម្មធនាគារពិភពលោក ក្នុងអំឡុងពេលរៀបចំគម្រោង
- ធ្វើសេចក្តីរាយការណ៍ ជូនក្រុមការងារគ.ជ.វ.វ និងគ.ជ.វ.វ អំពីលទ្ធផលការងារ រៀងរាល់ត្រីមាស ។

**ប្រការ ៣.-**

ឯកឧត្តម អស់លោក ដែលមានឈ្មោះនៅក្នុងប្រការ១ ខាងលើត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ថ្ងៃ ចុះហត្ថលេខា នេះតទៅ ។

**ប្រការ ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាព រហូតដល់ គម្រោង វិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដំណាក់កាលទី២ ត្រូវបានរៀបចំរួចរាល់ជាស្ថាពរ និងទទួលបានការអនុម័តជាផ្លូវការ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិ របស់គ.ជ.វ.វ ទាំងឡាយ ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**គណៈកម្មាធិការជាតិដឹកនាំការងារ**
**កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ**
**ប្រធាន**

**ស ខេង**

**កន្លែងទទួល:**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា (ដើម្បីជូនជ្រាប)
- សាមីខ្លួន (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ